# ព្រះរាជក្រម

នស/រកម/០៧០៧/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យ (១)-ក្រុមហ៊ុន ឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ិនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និង (២)-ក្រុមហ៊ុន យូណាន សោអ៊ុស-អេស៊ា អេកូណូមី អែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនផាសស្ត្រាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យ (១)-ក្រុមហ៊ុនឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និង (២)-ក្រុមហ៊ុនយូណាន សោអ៊ីស-អេស៊ា អេកូណូមិច អ៊ែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនដាសស្ត្រាល

មាត្រា ១.-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុនអគ្គិសនីកម្ពុជា ឱ្យ ៖

១-ក្រុមហ៊ុន ឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន ឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និងកិច្ចព្រមព្រៀងទិញលក់អគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុនឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។

២-ក្រុមហ៊ុន យូណាន សោអ៊ីស-អេស៊ា អេកូណូមិច អ៊ែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនដាសស្ត្រាល ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃ

ព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន ប៊ូណាន សោអ៊ីស-អេស៊ា អេក្វូឈ្វីទី អែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនជាសស្ត្រាល និងកិច្ចព្រមព្រៀងបញ្ចូនអត្ថិសទីរវាងក្រុមហ៊ុនអត្ថិសទីកម្ពុជា និងក្រុមហ៊ុន ប៊ូណាន សោអ៊ីស-អេស៊ា អេក្វូឈ្វីទី អែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនជាសស្ត្រាល ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ១៦ ខែ កុម្ភៈឆ្នាំ ២០០៧ ។

ការធានានេះមានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជាភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាខាងលើនេះ ។

**មាត្រា ៣.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧០៧.០១៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ៣០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**យុន ចិនគេន**